**ព្រឹត្តិប័ត្រព័ត៌មាន**
ក្រុមហ៊ុន **ហ្គ្រេនឌីស ធីមប៊ើរ អិលធីឌី**
ទីតាំងស្ថិតនៅក្នុង **ឃុំត្រាំងជីវ៉ាយ និងស្ទឹងសាមគ្គី** ស្រុក **ភ្នំស្រួច និងស្រុកឱរ៉ាល់**
ខេត្ត **កំពង់ស្ពឺ**

១-កម្មវត្ថុនៃការវិនិយោគ ៖ដំណាំឈើម៉ៃសាក់
២-ទំហំផ្ទៃដីក្នុងកិច្ចសន្យា ៖៩៨២០ ហិកតា (កិច្ចសន្យាចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩)
៣-ទំហំផ្ទៃដីអាជីវកម្ម-ផលិតកម្ម ៖ ៧៨៩៦,១១ ហិកតា (ចុះបញ្ជីរួច)
៤-គោលការណ៍វិនិយោគ(សជណ) ៖ លិខិតលេខ១១៩២ ស.ជ.ណ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពី ករណីសំណើសុំសម្បទានដីសេដ្ឋកិច្ច ១៧ ៣០២ ហិកតា របស់ក្រុមហ៊ុនហ្គ្រេន ឌីស ធីមប៊ើរ អិលធីឌី (Grandis Timber Ltd) សម្រាប់វិនិយោគដាំដុះឈើម៉ៃសាក់ មានទីតាំងស្ថិតនៅក្នុងស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។
៥-អនុក្រឹត្យស្តីពីអនុបយោគដី ៖ អនុក្រឹត្យលេខ ១៧៥ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការធ្វើអនុបយោគ។
៦-ការចុះបញ្ជីដីឯកជនរបស់រដ្ឋ ៖- បានចុះបញ្ជីរួចរាល់ ☒ នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៦ លើផ្ទៃដីទំហំ ៧៨៩៦,១១ ហិកតា មានចំនួន ១៧ប័ណ្ណ

- កំពុងអនុវត្តន៍ ☐ (ស្នើបញ្ជាក់ដំណើរការ និងផ្តល់ឯកសារ)...............
- មិនបានអនុវត្តន៍ ☐ ហេតុអ្វី? .......................................................

៧-លិខិតប្រទានសិទ្ធិ ៖ លិខិតលេខ ១០២ ស.ប្រទ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា
៨-កិច្ចសន្យា ៖- កិច្ចសន្យាដើមចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់រយៈពេល ៧០ឆ្នាំ លើផ្ទៃដី ៩ ៨២០ ហិកតា ដើម្បីវិនិយោគដាំដំណាំ ម៉ៃសាក់ ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- កិច្ចសន្យាកែសម្រួល ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ សម្រាប់រយៈពេល៥០ឆ្នាំ លើផ្ទៃដី៧ ៨៩៦១១,ហិកតា ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
៩-ប្រាក់កក់ធានាកិច្ចសន្យា ៖- បានបង់ប្រាក់កក់ជំនួន **៩៨ ២០០ USD** លេខវិក័យប័ត្រ ១២៣០៤៥ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១០(សក្ខីយប័ត្របង់ប្រាក់បានផ្តល់ជូន)។
១០-លិខិតឯកភាពលើផែនការមេ ៖- ផែនការមេកែតម្រូវកំពុងដំណើរការពិនិត្យ កែតម្រូវ អនុលោមតាមលិខិតលេខ ៧៦២០ .៤៨១ កសក/នផ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួង. កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- លិខិតលេខ ៣២៥៩/៣៣៦ កសក .រផ.ផក ចុះថ្ងៃទី០២ ខែ មិថុនា ឆ្នាំ ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១១-ផែនការសកម្មប្រចាំឆ្នាំ ៖ មាន ☒ គ្មាន ☐ (បើមានស្នើផ្តល់ឯកសារ) .............................................

១២-របាយការណ៍វាយតម្លៃហេតុ ៖ មាន ☒

- ក្រសួងបរិស្ថាន បានអនុម័តលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ តាមលិខិតលេខ ១៥៦២ សជណបស្ថ ចុះថ្ងៃទី០៦ ខែធ្នូ . ឆ្នាំ២០១៩

- ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩បានរៀបចំកិច្ចប្រជុំអន្តក្រសួង ដើម្បីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ។

- ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ បានរៀបចំកិច្ចប្រជុំបច្ចេកទេសនៅនាយកដ្ឋានវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីធ្វើការពិនិត្យ និងផ្តល់យោបល់បច្ចេកទេស។

- ថ្ងៃទី២៣ ខែសីហា ឆ្នា២០១៨ បានរៀបចំកិច្ចប្រជុំដើម្បីបង្ហាញលទ្ធផលនៃការសិក្សាវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ នៅសាលាខេត្តកំពង់ស្ពឺ។

- លិខិតលេខ. ៣៤១ សជណ.ប.ស្ថ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៨ ស្តីពីការអនុម័តលើទំហំនៃការសិក្សាផលប៉ះពាល់បរិស្ថាន និងសង្គម ពេញលេញ របស់គម្រោង។

- លិខិតលេខ ១៧២ សស្ថ ចុះថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០១៤ របស់.ណ ប.ជ. ក្រសួងបរិស្ថាន អនុម័តរបាយការណ៍ ESIA បឋម (របាយការណ៍ពេញលេញកំពុងដំណើរការជាមួយក្រុមហ៊ុន EIA)។

១៣-ប្រវត្តិសមាសភាពភាគហ៊ុន ៖ មាន ☒

ក-ដំណាក់កាលមុនចុះកិច្ចសន្យា ៖ - ក្រុមហ៊ុនបានចុះបញ្ជីពាណិជ្ជកម្ម តាមលិខិតលេខ ៦៤៨៣ ពណ.បចព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម

- តាមលក្ខន្តិកៈចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨៖

  - លោក Mikkel Otbo Nielsen ជាប្រធានក្រុមប្រឹក្សាភិបាលមានភាគហ៊ុនចំនួន ០០ ភាគហ៊ុន
  - លោក Daniel Keye Mitchell Jr ជាអភិបាល មានភាគហ៊ុន ចំនួន ០០ ភាគហ៊ុន

- លិខិតលេខ. ១១៦/០០៤ កសក.លស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការឯកភាពជាគោលការណ៍ទទួលស្គាល់លោក Timothy Andrew Fleming ជាប្រធានក្រុមប្រឹក្សាភិបាលថ្មីរបស់ក្រុមហ៊ុនហ្គ្រេនឌីស ធីមបើរ អិលធីឌី ជំនួសលោក Mikkel Otbo Nielsen ជាប្រធានក្រុមប្រឹក្សាភិបាលចាស់ និងតម្កល់លក្ខន្តិកៈក្រុមហ៊ុន។

ខ-ដំណាក់កាលចុះកិច្ចសន្យា ៖ - នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ក្រុមហ៊ុន បានចុះកិច្ចសន្យា ជាមួយ ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលមាន លោក Daniel Keye Mitchell Jr ជានាយកប្រត្តិបត្តិក្រុមហ៊ុន។

គ-ដំណាក់កាលក្រោយចុះកិច្ចសន្យា ៖ - ក្រោយពីចុះកិច្ចសន្យា ក្រុមហ៊ុនមិនមានការផ្លាស់ប្តូរសមាសភាពភាគហ៊ុននោះទេ ប៉ុន្តែបានប្តូរសមាសភាពក្រុមប្រឹក្សាភិបាលពីលោក Mikkel Otbo Nielsen ជាប្រធានក្រុមប្រឹក្សាភិបាល ជំនួសដោយលោក Timothy Andrew Fleming ជាប្រធានក្រុម ប្រឹក្សាភិបាលថ្មី តាមលក្ខន្តិកៈចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១០( លិខិតលេខ៦១៦/០០៤ កសក.លសចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ )

ឃ-លិខិតលេខ ១០៨៤ សជណ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ក្រុមហ៊ុនហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី បានចុះកិច្ចសន្យាកែតម្រូវនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧។

**តារាងផែនការប្រើប្រាសដីរបស់ក្រុមហ៊ុនតាមផែនការមេ**

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីអាជីវកម្ម-(ត.ហ)ផលិតកម្ម | ផ្ទៃដីផលិតកម្ម (ត.ហ) | ហេដ្ឋរចនាសម្ព័ន្ធ (ត.ហ) | ផ្ទៃដីតំបន់រក្សាទុក (ត.ហ) |
|---|---|---|---|---|---|
| ២០១០២០១៩- | I-XXIII | ៤៦២៣ | ៣៦៧១ | ១៣១ | ៨២១ |
| ២០២០ | I, XIX,XX, XII, XIV | ៦៦២ | ៥៥៤ | ២៤ | ៨៤ |
| ២០២១ | II, III, XXII , VII | ៧៩៧ | ៥៧៥ | ១៤ | ២០៨ |
| ២០២២ | IV, XV, XIII | ៦៧០ | ៥២៩ | ៤ | ១៣៧ |
| ២០២៣ | XI | ៦២២ | ៥៦១ | ៧ | ៥៤ |
| ២០២៤ | III , XIV, XVI, XVIII | ៥២២ | ៥២២ | 0 | 0 |
| **សរុប** | | **៧៨៩៦** | **៦៤១២** | **១៨០** | **១៣០៤** |

១៤-ការធ្វើសារពើភ័ណ្ឌព្រៃឈើក្នុងអនុតំបន់អនុញ្ញាតឲ្យឈូសឆាយ៖ បានធ្វើ ☐ មិនបានធ្វើ ☒

បើធ្វើក្នុងឆ្នាំ ............. (បើមានស្នើផ្តល់ឯកសារ បើគ្មានស្នើបញ្ជាក់មូលហេតុ)

១៥-ការដេញថ្លៃ / ពិគ្រោះថ្លៃឈើ និងបង់ថ្លៃសួយសារ-បុព្វលាភផល អនុផលព្រៃឈើ (ឈើឈរ)៖

ក-ការដេញថ្លៃ / ពិគ្រោះថ្លៃឈើ ៖ មាន ☐ គ្មាន ☒ ...................................................... (ស្នើផ្តល់ឯកសារ)

ខ-បង់ថ្លៃសួយសារ-បុព្វលាភផល អនុផលព្រៃឈើ៖ មាន ☐ គ្មាន ☒ .................................. (ស្នើផ្តល់ឯកសារ)

១៦-លិខិតអនុញ្ញាតឲ្យឈូសឆាយ ៖១. លិខិតលេខ.១៨៨ កសក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្ទៃដីទំហំ១២១២ ហិកតា ក្នុងអនុតំបន់ទី១៨, ១៩, ២០ និង ២២។

២. លិខិតលេខ.៤០១២/២៥៦ កសក.នផ.ផក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១៣ លើផ្ទៃដីទំហំ ២០០០ ហិកតា ក្នុងអនុតំបន់ទី ១៦ ១៧ និង ១៨។

៣. លិខិតលេខ. ៣២៥៩/៣៣៦ កសក.នផ.ផក ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើផ្ទៃដីទំហំ ៤០៧ ហិកតា ក្នុងអនុតំបន់ទី១, ២, ១១, ១៦, ១៧, ២១, និង ២៣។

១៧-ការអនុវត្តបាន៖

ក- ការឈូសឆាយនិងដាំដុះ៖

| ឆ្នាំ | អនុតំបន់ | ផ្ទៃដីអាជីវកម្ម-ផលិតកម្ម (ហ.ត) | ផ្ទៃដីអនុញ្ញាត (ហ.ត) | ផ្ទៃដីអនុវត្តបាន (ហ.ត) | | | | ផ្ទៃដីនៅសល់ (ហ.ត) | មូលហេតុ |
|---|---|---|---|---|---|---|---|---|---|
| | | | | ប្រភេទដំណាំ | ផ្ទៃដីឈូសឆាយ | ផ្ទៃដីបានដាំដុះ | ដាំដុះឡើងវិញ | | |
| 2010 | 11 | 720.52 | 407.00 | ម៉ៃសាក់ | 105.91 | 30.30 | | 75.61 | |
| 2011 | 1,2,3,4,5,6,7,8,9,10,11,13,16 | 586.01 | | ម៉ៃសាក់ | 1,784.40 | 1,286.13 | | 498.27 | |
| 2012 | 3,12,13,14 | 904.70 | | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 1,482.63 | 381.80 | | 1,100.83 | |
| 2013 | 3,11,12,13,14,17,18,21 | 1,058.31 | 2,000.00 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 974.56 | 1,626.38 | | (651.82) | |
| 2014 | 16,23 | 875.08 | | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 1,367.58 | 496.35 | | 871.23 | |
| 2015 | 11,18,21 | 961.71 | | ម៉ៃសាក់ និងប្រភេទផ្សេងៗ | | 500.34 | | (500.34) | |
| 2016 | 14,17,21 | 328.64 | | ម៉ៃសាក់ និងប្រភេទផ្សេងៗ | | 500.89 | | (500.89) | |
| 2017 | 5,6,9,11,12,23 | 31.35 | | ម៉ៃសាក់ និងប្រភេទផ្សេងៗ | | | 111.68 | - | |
| 2018 | 5,7,8,11,12,13,20,22 | 570.88 | 1,212.00 | ម៉ៃសាក់ និងប្រភេទផ្សេងៗ | 441.75 | 214.61 | 39.08 | 227.14 | |
| 2019 | 11,13,20,22 | 374.80 | | ម៉ៃសាក់ និងប្រភេទផ្សេងៗ | | 85.29 | 12.20 | (85.29) | |
| 2020 | 16 | | | ម៉ៃសាក់ និងប្រភេទផ្សេងៗ | | 88.27 | 13.33 | (88.27) | |
| **សរុប** | | **6,412.00** | **3,619.00** | | **6,156.83** | **5,210.36** | **176.29** | **946.47** | |

បញ្ជាក់៖ ស្នើបង្ហាញផែនទីទីតាំង និងចំណុចនិយាមកាបានអនុវត្តតាមតារាងខាងលើ

ខ- ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ៖ - សម្រាប់បីខែចុងក្រោយនេះ (តុលា ដល់ ធ្នូ) សម្រាប់ឆ្នាំ២០២១ ក្រុមហ៊ុនបានធ្វើការជួសជុលផ្លូវក្នុងសម្បទានដី សេដ្ឋកិច្ចចំនួនពីរខ្សែ ដែលមានប្រវែង ០,០៧៧ គ.ម ឬ៧៧ ម

- ចាប់តាំងពីខែមករា រហូតដល់ខែធ្នូ២០២១ ក្រុមហ៊ុនបានធ្វើការជួសជុលផ្លូវបាន ៣ខ្សែ ដែលមានប្រវែង ១៧គ.ម

គ-ការប្រើប្រាស់កម្លាំងពលកម្ម ៖ - ពលកម្មសរុបសម្រាប់ឆ្នាំ២០២១ មានចំនួន៦៦ នាក់ជាមធ្យម ដែលបុគ្គលិកអចិន្ត្រៃទាំងអស់ជាជនជាតិខ្មែរ។

- ចំនួនបុគ្គលិកបីខែចុងក្រោយ (តុលា ដល់ ធ្នូ) សម្រាប់ឆ្នាំ២០២១ ក្រុមហ៊ុនមានបុគ្គលិកខ្មែរសរុបទាំងអស់ចំនួន ៤៧នាក់។

- បុគ្គលិកខ្មែរ ៤៧ នាក់
- បុគ្គលិកបរទេស គ្មាន នាក់
- កម្មករខ្មែរអចិន្ត្រៃយ៍ គ្មាន នាក់
- កម្មករអណ្តែត គ្មាន នាក់

ឃ-ផ្ទៃដីប្រមូល ៖ ផ្ទៃដីប្រមូលផលសរុប គ្មាន ហ.ត ទិន្នផលសរុប គ្មាន តោន ក្នុងនោះមានៈ

- ដំណាំ .............គ្មាន......................... ផ្ទៃដីដាំដុះទំហំ ............ គ្មាន ហ.ត ប្រមូលផលឆ្នាំ .......គ្មាន................ ទិន្នផល គ្មាន .......................... តោន
- ដំណាំ ...............គ្មាន....................... ផ្ទៃដីដាំដុះទំហំ ............ គ្មាន ហ.ត ប្រមូលផលឆ្នាំ ........គ្មាន................ ទិន្នផល គ្មាន ......................... តោន
- ដំណាំ ...........គ្មាន........................... ផ្ទៃដីដាំដុះទំហំ គ្មាន............. ហ.ត ប្រមូលផលឆ្នាំ ........គ្មាន................ ទិន្នផល គ្មាន ......................... តោន

ង-ផលិតផលនាំចេញ ៖ ផលិតផលនាំចេញសរុប គ្មាន.................................. តោន ក្នុងនោះមានៈ

- ដំណាំ .....គ្មាន................. ចំនួន ....គ្មាន....... តោន នាំចេញឆ្នាំ គ្មាន ........
- ដំណាំ .......គ្មាន............... ចំនួន ....គ្មាន....... តោន នាំចេញឆ្នាំ គ្មាន ........
- ដំណាំ ......គ្មាន................. ចំនួន ....គ្មាន....... តោន នាំចេញឆ្នាំ គ្មាន ........

១៨-ថ្លៃឈ្នួលសម្បទានដីសេដ្ឋកិច្ច ៖

- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២០២០២០) -២០២១នូវទឹក ( ប្រាក់ចំនួន**៤១៤៤,៤៩៤. ដុល្លារអាមេរិក** នៅធនាគាជាតិនៃកម្ពុជា និង ធនាគារអេស៊ីលីដា ភីអិលស៊ី
- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ ២០១៩)-២០២០នូវទឹក ( ប្រាក់ចំនួន**៤១៦១,០៨៣. ដុល្លារអាមេរិក** នៅធនាគាជាតិនៃកម្ពុជា និង ធនាគារអេស៊ីលីដា ភីអិលស៊ី
- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៨ ២០១៧) - ២០១៨នូវទឹក ( ប្រាក់ចំនួន **៤០ ៦៧៦ ដុល្លារ ៨៤,អាមេរិក** នៅធនាគាជាតិនៃកម្ពុជា និង ធនាគារអេស៊ីលីដា ភីអិលស៊ី
- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៧ ២០១៦)-២០១៧ (លើទំហំ ទឹកប្រាក់ចំនួន **៤០ ២៧៤,១០ ដុល្លារអាមេរិក** នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៧ នៅធនាគារជាតិនៃកម្ពុជា និងធនាគារអេស៊ីលីដា ភីអិលស៊ី
- បង់ថ្លៃសម្បទានដីសេដ្ឋកិច្ចចំនួន០២ឆ្នាំសម្រាប់ឆ្នាំ២០១៥២០១៤)-២០១៥ ( និង២០១៦)២០១៥-២០១៦ចំនួន (ទឹកប្រាក់ **៧៩ ៣៥៥,៩០ដុល្លារអាមេរិក**

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ នៅធនាគារជាតិនៃកម្ពុជា និង ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ នៅធនាគារកាណាឌីយ៉ា ក.អ កម្ពុជា

១៩-រោងម៉ាស៊ីនអារកែច្នៃឈើ ៖- មាន □ លិខិតអនុញ្ញាតលេខ ..................... ចុះថ្ងៃខែឆ្នាំ ........................ របស់ ...................................................................... (ស្នើភ្ជាប់ឯកសារ)

- គ្មាន ☒

២០-ការកាត់ឆ្វៀល ៖- តាមបទបញ្ជា០១៖ មាន ☒ ឬ គ្មាន □

- ✓ ទំហំដីកាត់ឆ្វៀលតាមបញ្ជា ០១បប) និងកាត់ឆ្វៀលក្នុងអំឡុងពេលចុះបញ្ជីដីរដ្ឋ (សរុប **៦០៧ ២១, ហិកតា** នៅក្នុងអនុតំបន់ ១ ដល់ ៦
- ✓ ទំហំដីកាត់ឆ្វៀលចេញនៅភាគខាងជើងសម្បទានដីសេដ្ឋកិច្ច ៣០៨ហិកតា ក្នុងអនុតំបន់ទី ៩៤, ១០
- ✓ ប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចរបស់ LYP ទំហំ ១២០៨ ហិកតា ក្នុងអនុតំបន់ទី ៧០,
- ✓ តំបន់យកគ្រួសក្រសហម ២១៩ហិកតា ក្នុងអនុតំបន់ទី៧ ៧៤,
- ✓ សម្បទានសង្គមកិច្ច ១៩០ហិកតា ក្នុងអនុតំបន់ទី៧ ៧៩,
- ✓ តំបន់ការពារប្រភពទឹក ៤៧៦១០ ដល់ ១ ហិកតា ក្នុងអនុតំបន់ទី ៤៥,
- ✓ ទំហំដីនៅសល់ជាក់ស្តែងក្នុងតំបន់សម្បទានទំហំ **៧៨៩៦១,១** ហិកតា

- សម្រាប់ប្រទានកម្មជាកម្មសិទ្ធិ៖ មាន □ ឬ គ្មាន ☒

ផ្ទៃដីទំហំ ..........គ្មាន................ ហិកតា នៅក្នុងអនុតំបន់ គ្មាន .................

- តំបន់ធ្វើអាជីវកម្មរ៉ែ៖ មាន □ ឬ គ្មាន ☒

ផ្ទៃដីទំហំ .......គ្មាន.................. ហិកតា នៅក្នុងអនុតំបន់ គ្មាន .................

- តាមលិខិតលេខ ០៥ ប្រកព ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី៖ មាន □ ឬ គ្មាន ☒ ផ្ទៃដីទំហំ គ្មាន ហិកតា នៅក្នុងអនុតំបន់ ..
- ការកាត់ឆ្វៀលផ្សេងទៀតបម្រើឲ្យប្រយោជន៍សាធារណៈ ផ្លូវ វារីអគ្គីសនី បង្គោលអគ្គីសនី៖ មាន □ ឬ គ្មាន ☒ ផ្ទៃដីទំហំ គ្មាន..... ហិកតា ក្នុងអនុតំបន់

បញ្ជាក់៖ បើតំបន់សម្បទានដីសេដ្ឋកិច្ចមានពាក់ព័ន្ធនឹងករណីកាត់ឆ្វៀលណាមួយ ស្នើភ្ជាប់ឯកសារពាក់ព័ន្ធ និងផែនទីទីតាំងកាត់ឆ្វៀល។

២១-ការអនុវត្តបន្ទាប់ពីការណែនាំរបស់ប្រសួង ឬខេត្ត៖ (ស្នើផ្តល់ឯកសារ)

| ល.រ | លេខលិខិត | ខ្លឹមសារ | លទ្ធផលអនុវត្តតាមការណែនាំ |
|---|---|---|---|
| ១ | ៨០៤៥/៨២៤ កសក ចុះថ្ងៃទី ១១ កញ្ញា ២០២០ | កាតព្វកិច្ចបង់ថ្លៃដីសម្បទានសេដ្ឋកិច្ចជូនរដ្ឋសម្រាប់ឆ្នាំ២០២០ | • ក្រុមហ៊ុនបានឯកភាពចំពោះការគណនាចំនួនទឹកប្រាក់ដែលត្រូវបង់ថ្លៃដីសម្បទានដីសេដ្ឋកិច្ចឆ្នាំ ២០២០ (ឆ្នាំទី១១) ដោយឆ្លើយតបទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០២១។ |

២២-លទ្ធផលអនុវត្តខ្លឹមសារ សជណ តាមរបាយការណ៍របស់គណៈកម្មការអន្តរក្រសួង៖

| ល.រ | លេខលិខិត (សជណ) | ខ្លឹមសារសម្រេចរបស់ សជណ | លទ្ធផលអនុវត្តតាមការណែនាំ |
|---|---|---|---|
| ១ | លិខិតលេខ. ១០៨៤ សជណ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី | អនុញ្ញាតអោយក្រុមហ៊ុនហ្វ្រេនឌីសធីមប៉េីរ អិលធីឌី បន្តនីតិវិធីដោះស្រាយផលប៉ះពាលជា មួយ ប្រជាជន និងចុះកិច្ចសន្យាឡើងវិញដោយបន្ថយរយៈពេលពី៧០មកត្រឹម ៥០ឆ្នាំវិញ | • បានចុះបញ្ជីដីធ្លីរួចរាល់<br>• ធ្វើអនុបយោគរួចរាល់ពីដីសាធារណៈ មកជាដីឯកជនរបស់រដ្ឋ<br>• ចុះកិច្ចសន្យាកែតម្រូវ ថ្ងៃទី០១ខែធ្នូ ឆ្នាំ ២០១៧<br>• បញ្ចប់ផែនការមេថ្មី និងអនុម័តរួចរាល់ |

២៣-បញ្ហាទំនាស់ ការតវ៉ា ទាមទារដីធ្លី៖ មាន ☒ គ្មាន ☐

យោងតាមរបាយការណ៍ត្រីមាសទី៣ បញ្ហាដីធ្លីដែលកំពុងបន្តនីតិវិធីដោះស្រាយទាំងអស់មានចំនួន១៤៤ករណី ដែលក្នុងនោះមានបញ្ហាដីធ្លី១២០ករណីស្ថិតក្នុងស្រុកឱរ៉ាល់ និង២២ករណីទៀតស្ថិតក្នុងស្រុកភ្នំស្រួច។ ក្នុងត្រីមាសទី៤ ឆ្នាំ២០២១ ក្រុមហ៊ុនបានដោះស្រាយបញ្ហាដីធ្លីបានចំនួន ១៥ករណី។

ក្នុងចំណោមដីធ្លីដែលបានដោះស្រាយក្នុងត្រីមាសទី៤ ចំនួន ១៥ ករណី មាន៤ករណីស្ថិតក្នុងបញ្ហាដីធ្លីដែលកើតចេញពីការចុះបញ្ជីរជាប្រព័ន្ធ នៅក្នុងស្រុកឱរ៉ាល់។ ក្រុមហ៊ុនបានធ្វើការដោះស្រាយបញ្ហា៤ ករណីដែលជាន់ព្រំរវាងដីក្រុមហ៊ុន និងដីឯកជន ដោយការបោះបង្គោល យោងតាមព្រំសម្បទានដីសេដ្ឋកិច្ចដែលបានចុះបញ្ជីរ និងធ្វើអនុបយោគរួច។ ដូចនេះ បញ្ហាដីធ្លីដែលនៅសល់ចេញពីការចុះបញ្ជីរជាប្រព័ន្ធនៅក្នុងស្រុកឱរ៉ាល់មានចំនួន ១០៣ ដែលកំពុងដោះស្រាយ។

បញ្ហាដីធ្លីសរុបដែលជាន់ជាមួយសម្បទានដីសេដ្ឋកិច្ចក្នុងត្រីមាសទី៤ មានចំនួនសរុប ១២៩ ករណី។

ក្នុងបញ្ហាដីធ្លីចំនួន ១២៩ករណី ទំហំ ១៥២,២៣ហិកតា ដែលកំពុងបន្តនីតិវិធីដោះស្រាយនេះមាន៖

- ១០៧ ករណី (១០៣ ករណីចេញពីការចុះបញ្ជីរជាប្រព័ន្ធ និង ៤ករណីទៀតកើតមានស្រាប់)ស្ថិតក្នុងស្រុក ឱរ៉ាល់ (ទំហំ ១៤៣ហិកតា)
- ២២ ករណីស្ថិក្នុងស្រុកភ្នំស្រួច (ទំហំ ៩,២៤ហិកតា)

**វិធានការដោះស្រាយ និងលទ្ធផល**

ក្រុមហ៊ុនបានធ្វើការកំណត់នូវឫសគល់នៃបញ្ហា និងកត់ត្រានៅក្នុងតារាងតាមដានបញ្ហាដីធ្លីរបស់ក្រុមហ៊ុន។ នៅក្នុងដំណើរការកំណត់ឫសគល់នៃបញ្ហានៃទំនាស់ដីធ្លីនីមួយៗ ក្រុមហ៊ុនធ្វើឡើងដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន រដ្ឋបាលព្រៃឈើ ប្រជាជនពាក់ព័ន្ធ ដើម្បីពិនិត្យផលប៉ះពាល់ជាក់ស្តែងនៅទីវាល ប្រមូលឯកសារនៃការកាន់ (ភូមិ ឃុំ) កាប់ដីធ្លី និងឯកសារពាក់ព័ន្ធផ្សេងទៀត។

គិតត្រឹមត្រីមាសទី៤ឆ្នាំ២០២១ ក្រុមហ៊ុនបានខិតខំប្រឹងប្រែងធ្វើការដោះស្រាយ សម្របសម្រួលបញ្ហាមួយចំនួនតាមលទ្ធភាពដែលក្រុមហ៊ុនអាចធ្វើបាន។ ក្រុមហ៊ុនមិនត្រឹមតែបានដោះស្រាយបញ្ហាមួយចំនួនតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានអនុវត្តច្បាប់ក្នុងកម្រិតមូលដ្ឋានដោយ ដាក់បណ្តឹងទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

និងស្ថាប័នពាក់ព័ន្ធ ជំទាស់លើលទ្ធផលនៃវិនិច្ឆ័យក្បាលដីសម្រាប់ចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធបានជួបប្រជុំ , ជាមួយប្រធានក្រុមការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធថ្នាក់ស្រុកដើម្បីស្វែងយល់ពីបញ្ហា និងកំណត់ទិស និងផែនទី (ទំនាស់) ដោះដោះស្រាយបន្ត និងបានកំណត់មុខសញ្ញាអ្នកទាមទារ ទីតាំងទាមទារដើម្បីមានមូលដ្ឋានក្នុងរាយការណ៍ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីមានអន្តរាគមន៍។ បន្ថែមលើនេះទៀត តាម របាយការណ៍នៃកិច្ចប្រជុំក្រុមការងារអន្តរឃុំ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ បានផ្តល់អនុ (រស្មីសាមគ្គី និងក្រាំងដីវ៉ាយ) សាសន៍ដូចខាងក្រោម៖

- បញ្ហាដីធ្លីដែលស្ថិតនៅលើដីរដ្ឋដែលប្រជាជនមូលដ្ឋានបានដាក់ស្នើសុំកាត់ឆ្វៀលតាមអនុសាសន៍ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាល ត្រូវរង់ចាំការសម្រេចពីរាជរដ្ឋាភិបាល
- រៀបចំរបាយការណ៍ស្តីពីបញ្ហាដីធ្លីជាន់នឹងសម្បទានដីសេដ្ឋកិច្ចទាំងអស់ ជាពិសេសបញ្ហាដែលកើតចេញពីការត្រួតចុះបញ្ជីដីជាប្រព័ន្ធ គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត តាមរយៈរដ្ឋបាលស្រុកទាំងពីរ ដើម្បីស្នើសុំវិធានការដោះស្រាយ
- នៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១ ក្រុមហ៊ុនបានដាក់លិខិតគោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត តាមរយៈរដ្ឋបាលស្រុកឱរ៉ាល់ដើម្បីសុំអន្តរាគមន៍អំពីបញ្ហាដីធ្លីមានកើតមានក្នុងភូមិសាស្ត្រស្រុកឱរ៉ាល់។ បច្ចុប្បន្នក្រុមហ៊ុនមិនទាន់ទទួលបានការឆ្លើយតបពីឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តនៅឡើយទេ។
- នៅថ្ងៃទី២០ ខែកក្កដា ឆ្នា២០២១ ក្រុមហ៊ុនបានដាក់លិខិតគោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីស្នើរសុំកិច្ចអន្តរាគមន៍អំពីបញ្ហាដីធ្លី ក៏ដូចជាស្នើរសុំអោយក្រសួងចាត់វិធានការតាមនីតិវិធីច្បាប់ចំពោះបញ្ហាដីធ្លីដែលជាន់ប្លង់ជាមួយសម្បទានដីសេដ្ឋកិច្ចដែលបានចុះបញ្ជី និងធ្វើអនុបយោគរួច រាល់។ ប៉ុន្តែក្រុមហ៊ុនមិនទាន់ទទួលបានការឆ្លើយតបពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំពោះលិខិតរហូតមកដល់បច្ចុប្បន្ន។
- នៅថ្ងៃទី១១ ខែវិច្ឆកា ឆ្នាំ២០២១ ក្រុមហ៊ុនបានធ្វើរបាយការណ៍បច្ចុប្បន្នភាពស្តីពីបញ្ហាដីធ្លីទាំងអស់ដែលកើតមានឡើងជាន់ជាមួយសម្បទានដីសេដ្ឋកិច្ច ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីត្រួតពិនិត្យ និងសម្របសម្រួលក្នុងការដោះស្រាយលើបញ្ហាដីធ្លីទាំងអស់។ របាយការណ៍នេះត្រូវបានធ្វើឡើងដោយមានការផ្តល់យោបល់ពីលោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយយោងតាមស្មារតីអង្គប្រជុំនៅថ្ងៃ ០៨ ខែវិច្ឆិកា ឆ្នាំ២០២១ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ។

២៤-បទល្មើសព្រៃឈើ ៖ មាន ☒ គ្មាន ☐ អនុតំបន់ ........ ផ្ទៃដីទំហំ ........... ហិកតា ថ្ងៃខែឆ្នាំ ..............

- មានការលួចកាប់ឈើនៅតាមតំបន់ការពារប្រភពទឹក ដែលក្រុមហ៊ុនបានរក្សាទុកតាមតំបន់អូរដើម្បីការពារប្រភពទឹក។
- មានការលួចគាស់ឈើប្រណិតដែលក្រុមហ៊ុនបានរក្សាទុកតាមតំបន់អូរដើម្បីការពារប្រភពទឹក។
- មានការដាក់អន្ទាក់សត្វនៅក្នុងចម្ការឈើពាណិជ្ជកម្ម។

២៥-ផែនការអនុវត្តន៍បន្តរបស់ក្រុមហ៊ុន ៖បន្តធ្វើការដាំដុះតាមផែនការមេដែលបានកំណត់ បន្តសម្អាត និងថែទាំចម្ការ។

២៦-បញ្ហាប្រឈមរបស់ក្រុមហ៊ុន ៖ បញ្ហាប្រឈមរបស់ក្រុមហ៊ុននៅពេលនេះគឺបញ្ហាដីធ្លី ដែលបានបញ្ជាក់ដូចខាងលើ។ លើសពីនេះទៅទៀត ការលួចកាប់ឈើពាណិជ្ជកម្ម ក៏ដូចជាឈើប្រណិតនៅតាមតំបន់ការពារប្រភពទឹក ការបំផ្លាញទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដូចជា.

កាត់របង ដើម្បីធ្វើការដឹកឈើពីតំបន់ស្តារ ជាដើម។ បញ្ហាដុតចម្ការពាណិជ្ជកម្ម ក៏ជាបញ្ហាប្រឈមរបស់ក្រុមហ៊ុនផងដែរ។

២៧-សំណូមពររបស់ក្រុមហ៊ុន ៖

- ស្នើសុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជួយពន្លឿន និងសម្របសម្រួលឱ្យមានការដោះស្រាយបញ្ហាដីធ្លី ដែលជាន់ជាមួយសម្បទានដីសេដ្ឋកិច្ច ទៅតាមការទទូចសុំរបស់ក្រុមហ៊ុន ដោយយោងតាមស្មារតីអង្គប្រជុំនៅថ្ងៃទី០៨ វិច្ឆិកា ឆ្នាំ២០២១។
- ស្នើសុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជួយបន្តតាមដានឱ្យនភាពនៃលិខិតដែលក្រុមហ៊ុនបានដាក់ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអំពីបញ្ហាដីធ្លី ទៅតាមការស្នើសុំក្នុងខ្លឹមសារលិខិតដែលបានដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃទី២០ កក្កដា ឆ្នាំ២០២១។
- ស្នើសុំបន្ត និងពង្រឹងការចុះណែនាំអប់រំប្រជាពលរដ្ឋពីបញ្ហាបង្ករភ្លើងឆេះព្រៃ វាលស្មៅ ឬព្រៃតាមទ្រនាប់អូរ ដើម្បីជាប្រយោជន៍ចំណីសត្វពាហនៈឬគោលបំណងផ្សេងដែលបង្កជាហានិភ័យធ្ងន់ធ្ងរ។
- ស្នើសុំឱ្យមានវិធានការផ្លូវច្បាប់តឹងរឹងបំផុតចំពោះអ្នកបរបាញ់ ដាក់អន្ទាក់សត្វព្រៃ និងអ្នកដុតបំផ្លាញព្រៃឈើ ឬចម្ការឈើដាំរបស់ក្រុមហ៊ុនដោយចេតនា។

២៨-អាស័យដ្ឋានទំនាក់ទំនងក្រុមហ៊ុន៖

ក-ទីស្នាក់ការនៅភ្នំពេញ ៖ ផ្ទះ ៣៨ដេ/ អគារលេខ ........... ផ្លូវលេខ .......៤៩៤........ ភូមិ / ក្រុម ......... សង្កាត់ ....ផ្សារដើមថ្កូវ.................................... ខណ្ឌ ចំការមន ...............

ខ-ទីស្នាក់ការនៅខេត្ត ៖ ភូមិ / ក្រុម ......ដូង...................... ឃុំ / សង្កាត់ ក្រាំងដីវ៉ាយ ...................... ស្រុក / ខណ្ឌ ..........ភ្នំស្រួច......................... ខេត្ត កំពង់ស្ពឺ......................

គ-ទីស្នាក់ការនៅទីតាំងដីសម្បទាន៖ ចំណុចនិយាមកា XY (404498 ; 1269851) ផ្ទៃដីទំហំ ៧ ៨៩៦,១១ ហិកតា ភូមិ ដូង ឃុំ ក្រាំងដីវ៉ាយ ស្រុក ភ្នំស្រួច ខេត្ត កំពង់ស្ពឺ

ឃ-បុគ្គលិកទំនាក់ទំនង ៖ ឈ្មោះ ហុង លីណា តួនាទី ប្រធានប្រតិបត្តិលេខទូរស័ព្ទ ០១៧ ៦៦៦ ៤៣៥

Email hong.lina@grandistimber.com

ថ្ងៃ ...................... ខែ ............... ឆ្នាំ ......ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅ ................ ថ្ងៃទី .......... ខែ ............. ឆ្នាំ២០២១

**ប្រធានប្រតិបត្តិក្រុមហ៊ុន**